ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣៥៤

ចុះថ្ងៃទី ២១ ‸០៧ ‸២០០៦

សាលដីកា

លេខ : ៣៧ "ខ"

ចុះថ្ងៃទី ២១‸០៤‸២០១០

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២១-០៤-២០១០ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៣៥៤ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ដែលមាន:

- ជនជាប់ចោទឈ្មោះ[redacted]យ៉ុង ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិប្រាសាទ ឃុំព្រែកស្វែង ស្រុកកណ្តាលស្ទឹង ទីលំនៅសព្វថ្ងៃភូមិ[redacted]មុខរបរធ្វើស្រែ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ[redacted] (រ) ប្រពន្ធឈ្មោ[redacted]មានកូន ២នាក់ ទោសពីមុនគ្មាន។

<u>ត្រូវជាប់ចោទពីបទ:</u> ជេរប្រមាថ ប្រព្រឹត្តនៅភូមិព្រែកស្វែង ឃុំព្រែកស្វែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ជ្រែត ភេទស្រី អាយុ ៥៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិព្រែកស្វែង ឃុំព្រែកស្វែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣២ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ[redacted]យ៉ុង ជាជនជាប់ចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៦ ឡ ចុះថ្ងៃទី ១២-០៦-២០០៨ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។



Scanned with CamScanner

**៦ដំណើររឿងមានដូចតទៅ:**

កាលពីថ្ងៃទី ២៦-០៣-២០០៦ វេលាម៉ោង ៥ល្ងាចភ្លឺ ឈ្មោះ[redacted] ~~ជ្រែត បានជិះម៉ូតូទៅទិញផ្សិតនៅផ្ទះឈ្មោះ~~ [redacted] សំអុល នៅភូមិព្រែកស្លែង ក្រោយពេលទិញហើយឈ្មោះ [redacted] ជ្រែត នៅរង់ចាំមួយចំនួនទៀតដែលពុំទាន់បានយកផ្សិតមកលក់ឱ្យខ្លួន មួយសន្ទុះក្រោយមកឈ្មោះ [redacted] យ៉ុង ជាអ្នកទិញផ្សិតដែរបានជិះម៉ូតូមកដល់ ពេលនោះឈ្មោះ [redacted] ជ្រែត និងឈ្មោះ [redacted] យ៉ុង បានទាស់សម្ដីគ្នាទៅវិញទៅមក ស្រាប់តែឈ្មោះ [redacted] យ៉ុង បានជេរប្រមាថទៅលើឈ្មោះ [redacted] ជ្រែត រួចឈ្មោះ [redacted] យ៉ុង ក៏ជិះម៉ូតូចេញទៅវិញបាត់ទៅ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៦ ឡ ចុះថ្ងៃទី ១២-០៦-២០០៨ របស់សាលាដំបូងខេត្តកណ្ដាល ដែលបានសម្រេចសេចក្ដីដូចខាងក្រោម:**

១- ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ[redacted] យ៉ុង ភេទប្រុស អាយុ ៣៧ឆ្នាំ ដោយពិន័យជាប្រាក់ចំនួន ១.០០០.០០០ រៀល ប្រាក់ពិន័យនេះត្រូវបង្វិលចូលក្នុងថវិការដ្ឋ។

ពីបទ ជេរប្រមាថទៅលើឈ្មោះ [redacted] ជ្រែត ប្រព្រឹត្តនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០០៦។

ការផ្ដន្ទាទោសនេះតាមមាត្រា ៦៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២- បង្គាប់ឱ្យឈ្មោះ [redacted] យ៉ុង បង់ប្រាក់ចំនួន ៤០០.០០០រៀល ឱ្យទៅឈ្មោះ [redacted] ជ្រែត ជាសំណងជម្ងឺចិត្ត ការសុំលើសពីនេះបដិសេធចោល។

ក្នុងករណីរឹងរូសមិនព្រមអនុវត្តតាមត្រូវដាក់គុកបង្ខំរូបកាយតាមមាត្រា ៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងជនរងគ្រោះ សម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៣២ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] យ៉ុង ជាជនជាប់ចោទ ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៦ ឡ ចុះថ្ងៃទី ១២-០៦-២០០៨ របស់សាលាដំបូងខេត្តកណ្ដាល គ្រប់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted] យ៉ុង ឆ្លើយថា: ខ្លួនប្ដឹងឧទ្ធរណ៍មក. ព្រោះខ្លួនមិនមានកំហុសអ្វីទេ។ មុនពេលខ្លួនជេរឈ្មោះ [redacted] ជ្រែត ខ្លួនបានសួរគាត់ត្រឹមត្រូវ តែគាត់មិនឆ្លើយ ខ្លួនក៏ជេរគាត់ទៅ ខ្លួនជេររួច ខ្លួនក៏ឡើងម៉ូតូមកភ្នំពេញ។



Scanned with CamScanner

សំណូមពរ ខ្លួនសុំចប់តែម្តង ហើយសុំបង់ប្រាក់ពិន័យនៅពេលនេះតែម្តង ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជ្រែត ឆ្លើយថា: ឈ្មោះ [redacted] យ៉ុង មិនបានសួរខ្លួនមុនទេ គឺឈ្មោះ [redacted] យ៉ុង ជេរខ្លួនតែម្តង ។ សំណូមពរ សុំឱ្យតុលាការសម្រេចដូចតុលាការថ្នាក់ក្រោម ។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

មហាអយ្យការសាលាឧទ្ធរណ៍សូមសន្និដ្ឋានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៦ ឡ ចុះថ្ងៃទី ១២-០៦-២០០៨ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

**សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:**

១- បណ្តឹងឧទ្ធរណ៍លេខ ៣២ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] យ៉ុង ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២- តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃកើតហេតុថ្ងៃទី ២៦-០៣-២០០៦ ខ្លួនសួរជនរងគ្រោះរកអ្នកដែលថាខ្លួនដេញថ្លៃផ្ទុំត តែជនរងគ្រោះមិនប្រាប់ ខ្លួនក៏ជេររកមុខ និងជេរថា បើគ្មានអ្នកណានិយាយទេ មានតែមីរយ:ឯងប្រឌិតរឿងខ្លួនឯង ។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ជេរប្រមាថ ប្រព្រឹត្តនៅភូមិព្រែកស្លែង ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០០៦ តាមច្បាប់ស្តីពីវិសោធនកម្មមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ០៦ ឡ ចុះថ្ងៃទី ១២-០៦-២០០៨ របស់សាលាដំបូងខេត្តកណ្តាល សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**<u>វិនិច្ឆ័យសេចក្តី</u>**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣២ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] យ៉ុង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៦ "ឡ" ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណ: ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] យ៉ុង និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជ្រែត ។



Scanned with CamScanner

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់៕

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ០៤ ខែ ០៦ ឆ្នាំ២០១៤

ក្រឡាបញ្ជី

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]